## បត្យាប័ន៣៖ មូលដ្ឋាននៃការបដិសេធដាច់ខាតនូវបត្យាប័ន

(Mandatory Grounds for Extradition Denial)

១. បត្យាប័ន អាចប្រព្រឹត្តទៅបានត្រូវបំពេញនូវគោលការណ៍ double criminality បន្ថែមពីលើនេះ គេត្រូវពិចារណានូវមូលដ្ឋានមួយចំនួនទៀតដើម្បីសម្រេចផ្តល់បត្យាប័នឬមិនផ្តល់។ សន្ធិសញ្ញាស្តីពីបត្យាប័នចែងអំពីមូលដ្ឋានជាពីរប្រភេទ៖ មូលដ្ឋាននៃការបដិសេធដាច់ខាត (mandatory grounds /grounds for mandatory refusal) និងមូលដ្ឋានមិនដាច់ខាត/មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ (optional grounds/grounds for discretionary refusal)។ ប្រភេទទី១សំដៅដល់មូលដ្ឋានដែលអាជ្ញាធរត្រូវតែបដិសេធបត្យាប័ន។ ពាក្យដែលប្រើគឺ «ត្រូវតែ (shall) ឬមិនត្រូវ»។ រីឯប្រភេទទី២សំដៅដល់មូលដ្ឋានដែលផ្អែកតាមនេះ បត្យាប័នអាចត្រូវបានបដិសេធ។ ក្នុងន័យនេះ អាជ្ញាធរអាចអនុញ្ញាតបត្យាប័នតាមឆន្ទានុសិទ្ធិ (discretion)។ សម្រាប់ប្រភេទទី២ គេប្រើពាក្យ «អាច (might)»។ ក្រមនីតិវិធីព្រហ្មទណ្ឌប្រើពាក្យ «អាច» ទោះបីមូលដ្ឋានខ្លះ ចែងក្នុងសន្ធិសញ្ញាត្រូវបានចាត់ថាជាមូលដ្ឋានដាច់ខាត។

២. ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងមូលដ្ឋានចំនួន៣៖ បទល្មើសនយោបាយ (មាត្រា៥៧៣) ប្រព្រឹត្តក្នុងដែនដីនិងត្រូវបានជំនុំជម្រះជាស្ថាពរ (មាត្រា៥៧៤) បទល្មើសដែលអាជ្ញាយុកាលចោទប្រកាន់បានផុតរួចទៅហើយ (មាត្រា៥៧៥)។ ដើម្បីឲ្យងាយស្រួលយល់ មាត្រា៥៧៥ ត្រូវបានដកស្រង់ទាំងស្រុងដូចតទៅ៖ *បត្យាប័ន**មិនអាច**ធ្វើបានទេនៅក្នុងករណីដែលបណ្តឹងអាជ្ញាបានផុតរលត់តាមច្បាប់របស់រដ្ឋធ្វើសំណើ។ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា បត្យា**ប័នមិនអាច**ធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញា ត្រូវបានផុតរលត់តាមច្បាប់កម្ពុជា*។ សូមកត់សំគាល់ថា មាត្រាប្រើពាក្យ «មិនអាច»។ នៅមានពាក្យមួយចំនួនដែលត្រូវបានប្រើដែលមានន័យមិនច្បាស់ដូចជាពាក្យ «ជំនុំជម្រះជាស្ថាពរ»។

៣. គេគួរកត់សំគាល់ថាសន្ធិសញ្ញាស្តីពីបត្យាប័ន ចែងអំពីកាតព្វកិច្ចត្រូវធ្វើបត្យាប័ន[1]។ ទោះបីជាយ៉ាងនេះក្តី កាតព្វកិច្ចនេះមិនដាច់ខាតទេ ពីព្រោះត្រូវបំពេញលក្ខខណ្ឌមួយចំនួន។ បន្ថែមពីលើនេះ មូលដ្ឋានខ្លះ តម្រូវមិនឲ្យធ្វើបត្យាប័ន។

៤. អនុលោមតាមខ្លឹមសារនៃសន្ធិសញ្ញាទាំង៧ស្តីពីបត្យាប័នរវាងកម្ពុជានិងរដ្ឋបរទេស មានមូលដ្ឋានយ៉ាងតិចចំនួន១២សម្រាប់បដិសេធជាដាច់ខាតនូវបត្យាប័ន៖ បទល្មើសនយោបាយ[2], សំណើធ្វើ

---

[1] Treaty between the Kingdom of Cambodia and the Kingdom of Thailand on Extradition, 1999 (Cambodia-Thailand Treaty 1999), Clause 2.

[2] Cambodia-Thailand Treaty 1999, clause 3; Treaty between the Kingdom of Cambodia and the People's Republic of China on Extradition, 1999 (Cambodia-China Treaty 1999), clause 3; Treaty between the Kingdom of Cambodia and the Lao People's Democratic Republic on Extradition, 1999 (Cambodia-Lao Treaty 1999), clause 3; Agreement

ឡើងក្នុងគោលបំណងប្តឹងចោទដោយមូលហេតុពូជសាសន៍...ទស្សនៈនយោបាយរបស់បុគ្គល[3], បទល្មើសយោធា[4], រារាំងដោយច្បាប់ស្តីពីអាជ្ញាយុកាល[5], ចេញសាលក្រមដោយរដ្ឋទទួលសំណើមុនសំណើបត្យាប័ន[6] សាលក្រមកំបាំងមុខដោយរដ្ឋដាក់សំណើដោយគ្មានឱកាសក្នុងការជំនុំជម្រះឡើងវិញ[7] កាត់ទោសដោយតុលាការពិសេសដែលនឹងមិនមានការធានានូវនីតិវិធីត្រឹមត្រូវ[8], បុគ្គលដែលត្រូវធ្វើបត្យាប័នត្រូវបានធ្វើទារុណកម្ម...[9]ឬបញ្ជូនទៅទទួលទោសប្រហារជីវិត[10] បត្យាប័នប្រជាពលរដ្ឋ[11] និងបត្យាប័ននាំឲ្យប៉ះដល់សណ្តាប់ធ្នាប់សាធារណៈ[12]។

**៥**. សន្ធិសញ្ញាជាមួយឡាវ, ថៃនិងចិន មានចែងនូវមូលដ្ឋានទាំងពីរប្រភេទសម្រាប់បដិសេធបត្យាប័នក្នុងមាត្រាដោយឡែក ដែលនេះខុសពីសន្ធិសញ្ញារបស់កម្ពុជាជាមួយនឹងវៀតណាមនិងជាមួយរុស្ស៊ី។ មូលដ្ឋានទាំងពីរប្រភេទ ត្រូវបានចែងក្នុងមាត្រាតែមួយ។ ប្រភេទនិងខ្លឹមសារនៃមូលដ្ឋានសម្រាប់បដិសេធដាច់ខាត ត្រូវបានចែងស្រដៀងគ្នាក្នុងសន្ធិសញ្ញាជាមួយថៃ, ឡាវនិងចិន។ អ្វីជាការកត់សម្គាល់ ខណៈដែលទោសប្រហារជីវិត ជាមូលដ្ឋានសម្រាប់បដិសេធដោយឆន្ទានុសិទ្ធិ[13] សន្ធិសញ្ញាជាមួយវៀតណាមនិងជាមួយរុស្ស៊ីបានចែងខ្លឹមសារស្រដៀងគ្នានិងចាត់ជាមូលដ្ឋានសម្រាប់បដិសេធដាច់ខាត[14]។ ជាចុង

---

on Extradition between the Government of the Kingdom of Cambodia and the Government of the Republic of Korea, 2009 (Cambodia-Korea Agreement 2009), article 3; Treaty on Extradition between the Kingdom of Cambodia and the Socialist Republic of Viet Nam, 2013 (Cambodia-Viet Nam Treaty 2013) article 3; Treaty on Extradition between the Government of the kingdom of Cambodia and the Government of the republic of France, 2015 (Cambodia-France Treaty 2015), article 3.

[3] Cambodia-Thailand Treaty 1999, clause 3; Cambodia-China Treaty 1999, clause 3; Cambodia-Lao Treaty 1999, clause 3; Cambodia-Korea Agreement 2009, article 3; Cambodia-Viet Nam Treaty 2013, Article 3; Cambodia-France Treaty 2015, article 3; Treaty between the Kingdom of Cambodia and the Russian Federation on Extradition, 2017 (Cambodia-Russia Treaty 2017), article 5(1.c).

[4] Cambodia-Thailand Treaty 1999, clause 3; Cambodia-China Treaty 1999, clause 3; Cambodia-Lao Treaty 1999, clause 3; Cambodia-Korea Agreement 2009, article 3; Cambodia-Viet Nam Treaty 2013, article 3; Cambodia-France Treaty 2015), article 3.

[5] Cambodia-Thailand Treaty 1999, clause 3; Cambodia-China Treaty 1999, clause 3; Cambodia-Lao Treaty 1999, clause 3; Cambodia-Korea Agreement 2009, article 3; Cambodia-Viet Nam Treaty 2013, article 3; Cambodia-France Treaty 2015, article 3; Cambodia-Russia Treaty 2017, article 5 (1).

[6] Cambodia-Thailand Treaty 1999, clause 3; Cambodia-China Treaty 1999, clause 3; Cambodia-Lao Treaty 1999, clause 3; Cambodia-Korea Agreement 2009, article 3 (sentenced and dismissal); Cambodia-Viet Nam Treaty 2013, article 3 (innocent, already enforced sentence); Cambodia-France Treaty 2015, Article 3 (pardon); Cambodia-France Treaty 2015, article 3; Cambodia-Russia Treaty 2017, Article 5(1).

[7] Cambodia-Thailand Treaty 1999, clause 3; Cambodia-China Treaty 1999, clause 3; Cambodia-Lao Treaty 1999, clause 3; Cambodia-Korea Agreement 2009, article 3; Cambodia-France Treaty 2015, article 3.

[8] Cambodia-France Treaty 2015, Article 3(e).

[9] Cambodia-Viet Nam Treaty 2013, Article 3 (extradition to third country).

[10] Cambodia-France Treaty 2015, Article 5.

[11] Cambodia-Russia Treaty 2017, article 5(1).

[12] Cambodia-Russia Treaty 2017, Article 5(1.g).

[13] UN Model Treaty on Extradition, Resolution45/116, Article 4.

[14] Cambodia-Viet Nam Treaty 2013, Article 5.

ក្រោយ សន្ធិសញ្ញាបារាំងនិងកម្ពុជា បានចាត់ទោសប្រហារជីវិតជាមូលដ្ឋានសម្រាប់បដិសេធក្នុងមាត្រាដោយឡែក[15]។

៦. អ្នកនិពន្ធសូមធ្វើការកត់សំគាល់បន្ថែមចំនួនពីរចំណុចៈ **ទី១. ទោសប្រហារជីវិតជាមូលដ្ឋាននៃការបដិសេធៈ** ខណៈដែលសន្ធិសញ្ញាជាមួយវៀតណាមនិងជាមួយរុស្ស៊ី តម្រូវឲ្យធានាថាបុគ្គលនឹងមិនត្រូវកាត់ទោសប្រហារជីវិត សន្ធិសញ្ញាជាមួយប្រទេសបារាំង បានចែងយ៉ាងច្បាស់ថាៈ *ទោសនេះនឹងត្រូវបានជំនួសជាស្វ័យប្រវត្តិដោយទោសធ្ងន់ជាងគេ ដែលមានចែងក្នុងច្បាប់នៃភាគីទទួលសំណើ*។[16] សន្ធិសញ្ញាស្ដីពីបត្យាប័នប្រទេសខ្លះ ពាក់ព័ន្ធទោសប្រហារជីវិតចែងថាមិនត្រូវដាក់ទោសប្រហារជីវិត។ ក្នុងករណីដាក់ទោសប្រភេទនេះ នឹងមិនត្រូវអនុវត្តទេ។ **ទី២. ពាក់ព័ន្ធនឹងទារុណកម្មៈ** សន្ធិសញ្ញាជាមួយវៀតណាម មាត្រា៣(ច)៖*ភាគីទទួលសំណើមានមូលដ្ឋាន ដែលនាំឲ្យមានការជឿជាក់ថាបុគ្គល ដែលត្រូវធ្វើបត្យាប័ន ត្រូវបានធ្វើទារុណកម្មឬត្រូវបានដាក់ទណ្ឌកម្ម ឬផ្ដន្ទាទោសបែបព្រៃផ្សៃ ឬអមនុស្សធម៌ ឬ*[17]។ វាជាសញ្ញាណវិជ្ជមានមួយ ដែលមិនមានឃើញចែងក្នុងសន្ធិសញ្ញាជាមួយរដ្ឋបរទេសចំនួន៦ទៀតទេ។ នេះក៏ស្របនឹងកាតព្វកិច្ចក្នុងមាត្រា៣នៃអនុសញ្ញាស្ដីពីការបង្ការអំពើទារុណកម្មឆ្នាំ១៩៨៤។ ទោះបីជាយ៉ាងនេះក្ដី វាមានភាពមិនច្បាស់ថាតើវាជាអំពើទារុណកម្មក្នុងពេលអនាគតនៅក្នុងប្រទេសធ្វើសំណើ ក្រោយពីបុគ្គលដែលគេទាមទារ ត្រូវបានធ្វើបត្យាប័នចេញពីរដ្ឋទទួលសំណើ?

**៧.** សំណួរខាងវាពាក់ព័ន្ធនឹងការបកស្រាយខ្លឹមសារនៃសន្ធិសញ្ញា។ វិធានដែលត្រូវប្រើគឺមាត្រា៣១នៃសន្ធិសញ្ញាស្ដីពីច្បាប់សន្ធិសញ្ញា ដែលវិធាននេះ ត្រូវបានចាត់ថាជាវិធានទំនៀមទម្លាប់អន្តរជាតិ[18]។ ប្រទេសមួយចំនួនបានប្រកាន់យកគោលការណ៍បកស្រាយឲ្យស្របនឹងបទប្បញ្ញត្តិអន្តរជាតិ (principle of conformity)[19]។

៨. ក្នុងដំណើរការនៃការពិចារណាសម្រេចផ្ដល់ឬមិនផ្ដល់បត្យាប័ន រដ្ឋទទួលសំណើត្រូវពិចារណានូវលក្ខខណ្ឌឬកត្តាជាច្រើន។ ជាការអនុវត្ត អ្នកនិពន្ធមិនបានដឹងថាមូលដ្ឋានសម្រាប់បដិសេធនឹងត្រូវពិចារណាក្នុងដំណាក់កាលណាទេ។ អ្វីដែលច្បាស់ ដោយពិនិត្យមើលមាត្រា៣(ច)ក្នុងចំណុចទី៦ខាងលើ «...*មានមូលដ្ឋានដែលនាំឲ្យមានការជឿជាក់ថា*...» ចង់ឬមិនចង់ វាតម្រូវឲ្យរដ្ឋទទួលសំណើពិចារណានូវ

---

[15] Cambodia-France Treaty 2015, Article 5.
[16] Cambodia-France Treaty 2015, article 5.
[17] Cambodia-Viet Nam Treaty 2013, Article 3.
[18] United Nations, *Vienna Convention on the Law of Treaties*, United Nations, Treaty Series, vol. 1155, p. 331, 23 May 1969, https://www.refworld.org/legal/agreements/un/1969/en/73676 [accessed 15 April 2025; Panos Merkouris, Introduction: Interpretation as a Science, is an art, is a science, p. 8 in Malgosia Fitzmaurice, Olufemi Elias, Panos Merkouris, Treaty Interpretation and the Vienna Convention on the Law of Treaties: 30 Years on, 2010.
[19] David Sloss, The Role of Domestic Courts in Treaty Enforcement, A Comparative Study, the Netherlands, 2009, p. 349.

ស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋធ្វើសំណើ ដើម្បីដឹងថានឹងមានអំពើទារុណកម្មឬទេ? ប្រសិនបើអាច វាអាចផ្ទុយនឹងទស្សនៈឬជំហរបូរាណ ស្តែងតាមវិធានមិនជជែកវែកញែក (rule of non-inquiry) ឬការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ (principle of non-interference in domestic affairs of other State)។ វាជាការពិត នៅពេលរដ្ឋណាមួយចុះសន្និសញ្ញា វាជាការព្រមព្រៀមដោយប្រយោលរួចទៅហើយ (implied consent) ដូចនេះ ការណ៍ដែលរដ្ឋទទួលសំណើពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៃរដ្ឋធ្វើសំណើ រដ្ឋខាងក្រោយនេះ មិនអាចចោទរដ្ឋទទួលសំណើជ្រៀតជ្រែកកិច្ចការងារផ្ទៃក្នុងឡើយ។

៩. ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងអនុវត្តវិធានស្តីពីបត្យាប័នក្នុងក្រមនេះ ក្នុងករណីមិនមានសន្និសញ្ញា។ ដូចនេះប្រសិនបើមានសន្និសញ្ញា វិធានក្នុងសន្និសញ្ញានឹងត្រូវអនុវត្ត[20]។ គេអាចនិយាយថាបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ មានឋានៈទាបជាងបទប្បញ្ញត្តិក្នុងសន្និសញ្ញា[21]។ ក្នុងន័យនេះ ចម្លើយលើសំណួរ ថាការផុតអាជ្ញាយុកាលចោទប្រកាន់ ជាមូលដ្ឋានដាច់ខាតឬមិនដាច់ខាត ត្រូវបកស្រាយអនុលោមតាមសន្និសញ្ញា។ ស្រដៀងគ្នានេះដែរ សម្រាប់ទារុណកម្មជាមូលដ្ឋាននៃការបដិសេធដាច់ខាតនូវបត្យាប័នមិនមានចែងក្នុងសន្និសញ្ញារវាងកម្ពុជាជាមួយប្រទេស៦ទៀតលើកលែងសន្និសញ្ញាជាមួយវៀតណាម ចៅក្រមគួរបកស្រាយអនុលោមតាមអនុសញ្ញាស្តីពីការបង្ការអំពើទារុណកម្ម។

សូមមើលអត្ថបទមុនៗ ស្តីពី បត្យាប័ន និង គោលការណ៍ Double Criminality។

[20] Code of Criminal Procedure of Cambodia, 2007, Article 567.

[21] Law on Copy Rights and Related Rights of Cambodia, 2003, Article 67.